# មានតែពាក្យថាចប់

*ពាក្យ៨*

*ជួបមុខរាក់ទាក់ជំពាក់ចិត្ត*
*យល់ថ្លើមផ្តើមផ្ចិតអាណិតខ្លាំង*
*ញញឹមសាកសួរផ្តល់កំលាំង*
*ផ្តួចផ្តើមតតាំងសុំរាប់អាន។*
*ក្តិក្តក់ឱដងឆ្លងសំដី*
*រីករាយប្រិមប្រិយស្រស់ឥតស្រាន្ត*
*នាំឲ្យស្គាល់ផ្ទះស្រុកភូមិដ្ឋាន*
*សំពះសន្តានបានស្គាល់គ្នា។*
*សាកសួរប្រវត្តិឃាត់នៅបាយ*
*សើចលេងក្អាកក្អាយទាំងមីងមា*
*ពុកម៉ែបងប្អូនសើចគ្រប់គ្រា*
*មួយថ្ងៃជួបជាលាផ្តែផ្តាំ។*
*រូបស្រស់ឈ្មោះល្បីស្រីឈានមុខ*
*ប្រុសៗកើតទុក្ខខ្វុកខ្វិចខ្វាំ*
*ចង់ស្តីសាសងប៉ងច្រើនឆ្នាំ*
*សំបុត្របួនប្រាំចាំចំឡើយ។*
*ប្រុសខ្លះខូចចិត្តត្បិតស្រីស្រស់*
*មិនអាណិតសោះម៉្លោះតោះតើយ*
*ប្រុសខ្លះឈប់រៀនព្រោះត្រានត្រើយ*
*ខ្លះមករៀនហើយមើលតែមុខ។*
*សំឡក់សំលឹងប្រឹងគួរគិត*
*ចំណងស្នេហ៍ស្និទ្ធរិតរុំទុក្ខ*
*វង្វេងវិលឡប់ចប់ទំនុក*
*គាំងដូចជាប់គុកស្នេហ៍ពីសី។*
*សក់ខ្មៅដូចគ្រាក់ធ្លាក់រំសាយ*
*វែងគ្របរាងកាយឆាយឆោមស្រី*
*សាច់សទ្រលុកមុខល្អខ្ចី*
*កែវភ្នែកប្រិមប្រិយបីគាប់ស្នេហ៍។*
*រូបរាងសម្ផស្សស្រស់លើសលោះ*
*សំដីពីរោះរៀនពូកែ*
*ប្រុសណាមិនបាក់ធ្លាក់ក្នុងស្នេហ៍*
*ស្គាល់យូរកាន់តែគួរស្រលាញ់។*
*អូនហើយពីមុនគន់គិតក្រ*
*ប្រាប់ដោយស្មោះសបងចុះចាញ់*
*ស្នេហ៍ក្តៅព្រឺព្រួចស្រលាញ់*
*ដេកដួលខ្នួរខ្នាញ់សំណាញ់ស្នេហ៍។*
*រៀនឆ្នាំទីបីស្រីផ្លាស់ប្លែក*
*ចេះតែដើរបែកលែងចង់ក្បែរ*

លែងស្ដីបញ្ជោរពោលពាក្យស្នេហ៍
ជួបមុខគិតតែពោលពាក្យលា។
អូនសើចញញឹមដាក់គេថ្មី
បងកាត់សំដីឈប់នឹកនា
គ្មានរឿងហេតុសោះម៉្លោះបែកគ្នា
ឲ្យបងគ្រាំគ្រាគ្មានពេលល្ហើយ។
ស្រីក៏បែខ្នងប្រលងក៏ធ្លាក់
ប្អូនប្រាំពីរនាក់ឈប់រៀនហើយ
ទោះជានៅរៀនក៏គ្មានត្រើយ
ឃើញបងស្រោប់ហើយជាគំរូ។
ម៉ែឪពីរទ្វេរគេទាប្រាក់
ធ្លាប់ខ្ចីបណ្ដាក់ឆ្នាំច្រើនយូរ
ដើម្បីកូនខ្ពស់រស់តស៊ូ
កូនឲ្យគំរូម៉ែក្អួតឈាម។
ក្មេងរៀនពេញស្រុកពុកម៉ែហាម
ក្មេងធ្វើទៅតាមមិនតោងទាម
ពុកឲ្យឈប់រៀនក៏ឈប់ភ្លាម
សាលាស្ងួតក្រៀមមានតែគ្រូ។
ទៅណាមកណាគេសាកសួរ
តឹងកគ្រងួរទុក្ខទំទូរ
ខ្មាសញាតិចាស់ក្មេងសួររអ៊ូ
គេធ្លាប់ហៅគ្រូបែជាធ្លាក់។
សល់តែរអាស្រូវនៅរយឆ្នាំ
មិនអាចកាត់ដាំប្រែផ្លាស់លាក់
ឲ្យល្អដូចដើមធ្មើមជឿជាក់
កេរ្ដិ៍ឈ្មោះអស់លក្ខណ៍គ្មានថ្ងៃប្រែ។

ភ្នំពេញ ១៣ កម្ភៈ ២០០៥
សូយ ឡូត